**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់**
**កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ**
**(MAFF-NIO for Rice-SDP)**

លេខ: ......០២៦......... កពស/រប

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**<u>កម្មវត្ថុ</u>**: របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមរាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រីអំពីសកម្មភាព និងលទ្ធផលការងារនៃការអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ប្រចាំឆ្នាំ២០១៥ ដែលមានដូចខាងក្រោមនេះ៖

## I)- ការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ និងលទ្ធកម្ម

### ១)- ការងាររដ្ឋបាល

១.១- ស្ថានភាពថ្នាក់ដឹកនាំ និងបុគ្គលិក MAFF-NIO

អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (MAFF-NIO) មានមន្ត្រីបម្រើការសរុបចំនួន១៣រូប ដែលក្នុងនោះមាន៖ នាយកគម្រោងចំនួន០១រូប នាយករងគម្រោងចំនួន០១រូប ប្រធានសម្របសម្រួលកម្មវិធីគម្រោងចំនួន០១រូប ប្រធានផ្នែករដ្ឋបាល គណនេយ្យនិងហិរញ្ញវត្ថុចំនួន០១រូប ប្រធានផ្នែកផែនការនិងអនុវត្តគម្រោងចំនួន០១រូប មន្ត្រីរដ្ឋបាលចំនួន០១រូប មន្ត្រីបច្ចេកទេសចំនួន០៦រូប និងមន្ត្រីស្ម័គ្រចិត្តចំនួន០១រូប។

១.២- ទីប្រឹក្សាថ្នាក់ជាតិ

អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (MAFF-NIO) បានជ្រើសរើសអ្នកជំនាញការផ្នែកគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុចំនួន០១រូប ដែលបានមកបម្រើការងារចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។

១.៣- សកម្មភាពរបស់បុគ្គលិក និងទីប្រឹក្សា

**+ វត្តមាននៅអង្គភាព MAFF-NIO**

វត្តមានរបស់មន្ត្រីមកបម្រើការងារនៅអង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (MAFF-NIO) មានដូចក្នុងបញ្ជីវត្តមានជូនភ្ជាប់។

**+ កិច្ចប្រជុំការងារផ្សេងៗនៅអង្គភាព MAFF-NIO:**

នៅក្នុងឆ្នាំ២០១៥ អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (MAFF-NIO) បានអនុវត្តកិច្ចប្រជុំផ្សេងៗចំនួន៣០លើក។

+ កិច្ចប្រជុំ/សិក្ខាសាលានៅថ្នាក់ខេត្តដែលរៀបចំដោយអង្គភាព MAFF-NIO:

នៅក្នុងឆ្នាំ២០១៥ អង្គភាព MAFF-NIO បានរៀបចំកិច្ចប្រជុំ/សិក្ខាសាលានៅថ្នាក់ខេត្តចំនួន០៦វគ្គ រួមមាន៖

- ថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១៥: បានរៀបចំសិក្ខាសាលាស្តីពីការណែនាំ និងផ្សព្វផ្សាយការកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរ នៅខេត្តកំពង់ធំ
- ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥: បានរៀបចំសិក្ខាសាលាស្តីពីការណែនាំ និងផ្សព្វផ្សាយការកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរ នៅខេត្តព្រៃវែង
- ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥: បានរៀបចំសិក្ខាសាលាស្តីពីការណែនាំ និងផ្សព្វផ្សាយការកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរ នៅខេត្តបាត់ដំបង
- ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥: បានរៀបចំកិច្ចប្រជុំរៀបចំបង្កើតក្រុមការងារអនុវត្តការវិភាគប្រព័ន្ធកសិត្រ បរិស្ថាន នៅខេត្តកំពង់ធំ
- ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥: បានរៀបចំកិច្ចប្រជុំរៀបចំបង្កើតក្រុមការងារអនុវត្តការវិភាគប្រព័ន្ធកសិត្រ បរិស្ថាន នៅខេត្តបាត់ដំបង
- ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥: បានរៀបចំកិច្ចប្រជុំរៀបចំបង្កើតក្រុមការងារអនុវត្តការវិភាគប្រព័ន្ធកសិត្រ បរិស្ថាន នៅខេត្តព្រៃវែង។

+ ការចូលរួមប្រជុំ/សិក្ខាសាលានៅថ្នាក់កណ្តាលរបស់មន្ត្រីអង្គភាព MAFF-NIO:

នៅក្នុងឆ្នាំ២០១៥ មន្ត្រីនៃអង្គភាព MAFF-NIO បានចូលរួមកិច្ចប្រជុំផ្សេងៗដែលរៀបចំឡើងដោយអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រួមមាន៖

- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥: បានចូលរួមកិច្ចប្រជុំរួមគ្នាមួយ (Consolidation Meeting) រវាងមន្ត្រីនៃ PMO និងក្រុមទីប្រឹក្សាបច្ចេកទេស (Technical Advisors)
- ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥: បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យឡើងវិញនូវការអនុវត្តសកម្មភាពការងារប្រចាំត្រីមាស (Quarterly Porfolio Performance Review) ដែលរៀបចំឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅទីស្នាក់ការធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- ថ្ងៃទី០៥ និង ០៩ ខែតុលា ឆ្នាំ២០១៥: បានចូលរួមក្នុងកិច្ចប្រជុំបើក (Kick-Off Meeting) និងកិច្ចប្រជុំបូកសរុប (Wrap-Up Meeting) ជាមួយក្រុមបេសកកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីតាមដាន និងត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) នៅអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO)
- ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥: បានចូលរួមក្នុងសិក្ខាសាលាស្តីពី Procurement Clinic ដែលរៀបចំឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅទីស្នាក់ការធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

+ ការចូលរួមប្រជុំ/សិក្ខាសាលានៅថ្នាក់ខេត្តរបស់មន្ត្រីអង្គភាព MAFF-NIO:

- ថ្ងៃទី១៦ ដល់ ២០ ខែមិនា ឆ្នាំ២០១៥: បានចូលរួមសិក្ខាសាលាស្តីពីការងារលទ្ធកម្ម នៅខេត្តព្រះសីហនុ ដែលរៀបចំឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- ថ្ងៃទី២៨ ខែកញ្ញា ដល់ ០២ ខែតុលា ឆ្នាំ២០១៥: បានចូលរួមសិក្ខាសាលាស្តីពីនីតិវិធីនៃការដកចំណាយដែលជាជំនួយឥតសំណង និងកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ខេត្តសៀមរាប ដែលរៀបចំឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

- ថ្ងៃទី១៦ ដល់២០ ខែវិច្ឆិកា ឆ្នាំ២០១៥: បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំ។

**+ ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលរបស់មន្ត្រីអង្គភាព MAFF-NIO:**

នៅក្នុងឆ្នាំ២០១៥ មន្ត្រីនៃអង្គភាព MAFF-NIO បានទទួលការបណ្តុះបណ្តាលចំនួន០៤វគ្គគឺ៖

- ថ្ងៃទី២៨ ដល់ ២៩ ខែឧសភា ឆ្នាំ២០១៥: បានទទួលការបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការដកចំណាយ និងការគ្រប់គ្រងហិរញ្ញវត្ថុ ដែលរៀបចំឡើងដោយអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO)
- ថ្ងៃទី២២ ដល់ ២៣ ខែកក្កដា ឆ្នាំ២០១៥: បានទទួលការបណ្តុះបណ្តាលស្តីពីការងារលទ្ធកម្ម នៅខេត្តបាត់ដំបង ដែលរៀបចំឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- ថ្ងៃទី១១ ដល់ ១៣ ខែវិច្ឆិកា ឆ្នាំ២០១៥: បានទទួលការបណ្តុះបណ្តាលអំពីកម្មវិធី Sage 50 Quantum 2015 (Peachtree) ដែលរៀបចំឡើងដោយអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO)។

**+ ការចុះបំពេញបេសកកម្មទៅថ្នាក់ក្រោមជាតិ**

នៅក្នុងឆ្នាំ២០១៥ មន្ត្រីនៃអង្គភាព MAFF-NIO បានចុះបំពេញបេសកកម្មទៅកាន់ខេត្តគោលដៅអនុវត្តគម្រោង ដូចខាងក្រោម៖

- ថ្ងៃទី២៥ ដល់ ២៩ ខែឧសភា ឆ្នាំ២០១៥: បានចូលរួមជាមួយក្រុមជំនាញការបច្ចេកទេសចុះពិនិត្យ និងកសាងផែនការសកម្មភាពការងាររបស់គម្រោង Rice-SDP នៅខេត្តបាត់ដំបង
- ថ្ងៃទី២២ ដល់ ២៤ ខែមិថុនា ឆ្នាំ២០១៥: បានចុះពិនិត្យ និងពិភាក្សាការងារជាមួយមន្ត្រីអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) ថ្នាក់ខេត្ត នៅខេត្តកំពង់ធំ
- ថ្ងៃទី២៩ ខែមិថុនា ដល់ ០២ ខែកក្កដា ឆ្នាំ២០១៥: បានចុះពិនិត្យ និងពិភាក្សាការងារជាមួយមន្ត្រីអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ (Rice-SDP) ថ្នាក់ខេត្ត នៅខេត្តបាត់ដំបង
- ថ្ងៃទី០៦ ដល់ ០៧ ខែកក្កដា ឆ្នាំ២០១៥: បានចុះពិនិត្យ និងពិភាក្សាការងារជាមួយមន្ត្រីអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ (Rice-SDP) ថ្នាក់ខេត្ត នៅខេត្តព្រៃវែង
- ថ្ងៃទី២១ ដល់ ២៤ ខែកក្កដា ឆ្នាំ២០១៥: បានចុះពិនិត្យ និងពិភាក្សាការងារជាមួយមន្ត្រីអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ (Rice-SDP) ថ្នាក់ខេត្ត នៅខេត្តបាត់ដំបង
- ថ្ងៃទី៣០ ដល់ ៣១ ខែកក្កដា ឆ្នាំ២០១៥: បានចុះពិនិត្យ និងពិភាក្សាការងារជាមួយមន្ត្រីអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ (Rice-SDP) ថ្នាក់ខេត្ត នៅខេត្តព្រៃវែង
- ថ្ងៃទី០៥ ដល់ ០៧ ខែសីហា ឆ្នាំ២០១៥: បានចុះពិនិត្យ និងពិភាក្សាការងារជាមួយមន្ត្រីអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ (Rice-SDP) ថ្នាក់ខេត្ត នៅខេត្តកំពង់ធំ
- ថ្ងៃទី០៦ ដល់ ០៩ ខែតុលា ឆ្នាំ២០១៥: បានចុះប្រមូលព័ត៌មាន និងពិនិត្យស្ថានភាពបច្ចុប្បន្ននៃការដាំដុះដំណាំស្រូវតាមសហគមន៍កសិកម្ម នៅខេត្តបាត់ដំបង
- ថ្ងៃទី១៦ ដល់ ១៨ ខែវិច្ឆិកា ឆ្នាំ២០១៥: បានចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីពីផលិតកម្មពូជស្រូវ និងទីតាំងសាងសង់ឡសម្ងួត នៅក្នុងស្រុកស្ទោង និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
- ថ្ងៃទី១៦ ដល់ ២០ ខែវិច្ឆិកា ឆ្នាំ២០១៥: បានចុះប្រមូលព័ត៌មាន និងពិនិត្យស្ថានភាពបច្ចុប្បន្ននៃការដាំដុះដំណាំស្រូវ និងការគ្រប់គ្រងតាមសហគមន៍កសិកម្ម នៅខេត្តកំពង់ធំ
- ថ្ងៃទី១៦ ដល់ ១៧ ខែធ្នូ ឆ្នាំ២០១៥: បានចុះប្រមូលព័ត៌មាន និងពិនិត្យស្ថានភាពបច្ចុប្បន្ននៃការដាំដុះដំណាំស្រូវ និងបច្ចេកទេសសម្ងួត និងស្តុកទុកគ្រាប់ពូជស្រូវតាមសហគមន៍កសិកម្ម។

+ លិខិតចេញ-ចូល

ដោយសារមានការពន្យាពេលក្នុងការអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) អង្គភាព MAFF-NIO បានចាប់ផ្តើមដំណើរការសកម្មភាពការងាររបស់ខ្លួនពេញលេញចាប់ពីខែឧសភា ឆ្នាំ២០១៤ រហូតមកដល់ពេលបច្ចុប្បន្ន។ នៅក្នុងរយៈពេលនេះ អង្គភាព MAFF-NIO បានរៀបចំលិខិតចេញសរុបចំនួន១០០ច្បាប់ ដែលក្នុងនោះ ៧៧ច្បាប់ជាលិខិតផ្ញើទៅកាន់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពគ្រប់គ្រងនិងសម្របសម្រួលការអនុវត្តកម្មវិធី (PMO) អង្គភាពអនុវត្តន៍កម្មវិធីថ្នាក់ខេត្ត (PIO) នៃខេត្តគោលដៅទាំងបី (ខេត្តកំពង់ធំ បាត់ដំបង និងព្រៃវែង) និងអង្គភាពពាក់ព័ន្ធមួយចំនួនទៀត និង២៣ច្បាប់ទៀតជាលិខិតបញ្ជាបេសកកម្ម។ ក្រៅពីនេះ អង្គភាព MAFF-NIO បានទទួលលិខិតចូលសរុបចំនួន២៤ច្បាប់ មកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពគ្រប់គ្រងនិងសម្របសម្រួលការអនុវត្តកម្មវិធី (PMO) អង្គភាពអនុវត្តន៍កម្មវិធីថ្នាក់ខេត្ត (PIO) នៃខេត្តគោលដៅទាំងបី និងអង្គភាពពាក់ព័ន្ធមួយចំនួនទៀត។

## ២)- ការងារគណនេយ្យ និងហិរញ្ញវត្ថុ

### ២.១- ការងារលិខិតស្នាមផ្សេងៗក្នុងការស្នើសុំ និងការចំណាយថវិកា

ចាប់ពីខែឧសភា ឆ្នាំ២០១៤ មកដល់ដាច់ឆ្នាំ២០១៥ អង្គភាព MAFF-NIO បានចេញលិខិតស្នើសុំ និងចំណាយថវិកាចំនួន៣៤ច្បាប់។

ក្រៅពីនេះ អង្គភាព MAFF-NIO បានរៀបចំសំណើសុំថវិកាមួយចំនួនទៀតសម្រាប់ទូទាត់លើចំណាយបន្ទាប់បន្សំលើការងាររដ្ឋបាល និងចំណាយបេសកកម្មរបស់មន្ត្រីក្នុងអង្គភាព MAFF-NIO ជារៀងរាល់ខែ។

### ២.២- ថវិកាបានទទួល

អង្គភាព MAFF-NIO មានប្រភេទគណនី Imprest Account ដែលមានអនុគណនីចំនួន០៣ (ប្រភពហិរញ្ញប្បទាន: ADB Loan 3007-CAM (SF), GAFSP Grant 0349-CAM (EF) និង Loan 8271-CAM (SCF) នៅធនាគារអេស៊ីលីដា ភីអិលស៊ី និងគណនីបដិភាគរាជរដ្ឋាភិបាលចំនួន០១ នៅធនាគារជាតិនៃកម្ពុជា សម្រាប់ទទួល និងរក្សាទុកថវិកាអនុវត្តសកម្មភាពគម្រោង។

- ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤: អង្គភាព MAFF-NIO បានទទួលថវិកាចំនួន ១៦៨.៥១៩ ដុល្លារអាមេរិក ពីប្រភពហិរញ្ញប្បទាន GAFSP Grant 0349-CAM (EF)
- ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤: អង្គភាព MAFF-NIO បានទទួលថវិកាចំនួន ១៣២.២០៣ ដុល្លារអាមេរិក ពីប្រភពហិរញ្ញប្បទាន ADB Loan 3007-CAM (SF)
- ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥: អង្គភាព MAFF-NIO បានទទួលថវិកាចំនួន ៩០.៦៨០ ដុល្លារអាមេរិក ជាថវិកាបដិភាគរបស់រាជរដ្ឋាភិបាល។

ដូចនេះ ថវិកាសរុបដែលអង្គភាព MAFF-NIO ទទួលបានមានចំនួន ៣០០.៧២២ ដុល្លារអាមេរិកនៅធនាគារអេស៊ីលីដា ភីអិលស៊ី ក្នុងឆ្នាំ២០១៤ និង ៩០.៦៨០ ដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា ក្នុងឆ្នាំ២០១៥។

### ២.២- ថវិកាបានចំណាយ

រហូតមកដល់ដើមឆ្នាំ២០១៥ ទើបអង្គភាព MAFF-NIO មានប្រតិបត្តិការចំណាយដែលភាគច្រើនគឺទៅលើការរៀបចំសិក្ខាសាលា/កិច្ចប្រជុំតាមខេត្តគោលដៅ ការចុះបំពេញបេសកកម្មតាមខេត្តគោលដៅ ប្រាក់បៀវត្សរបស់មន្ត្រីអនុវត្តគម្រោង ការទូទាត់ទៅលើថ្លៃទិញគ្រាប់ស្រូវពូជ ការទូទាត់ទៅលើថ្លៃទិញរថយន្ត និងចំណាយបន្ទាប់បន្សំលើការងាររដ្ឋបាលប្រចាំថ្ងៃនៅក្នុងអង្គភាព។ នៅក្នុងឆ្នាំ២០១៥ ថវិកាដែលអង្គភាព MAFF-NIO បានចំណាយសរុបមានចំនួន ២៥៨.០៨២,៩០ ដុល្លារអាមេរិក ដែលក្នុងនោះ៖

- ចំណាយចេញពី GAFSP Grant 0349-CAM (EF) មានចំនួន ១០៥.៨៣៩,៩០ ដុល្លារអាមេរិក សម្រាប់ចំណាយលើការរៀបចំសិក្ខាសាលា និងការទូទាត់ថ្លៃគ្រាប់ស្រូវពូជ (Certified Rice Seed) (ដោយរាប់បញ្ចូលទាំងថវិកាចំនួន ៧០.០០០ ដុល្លារអាមេរិកដែលអង្គភាព MAFF-NIO បានផ្ទេរទៅគណនីរបស់ PMO (យោងលិខិតលេខ០៤១/១៥ PMO/MEF ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ របស់អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO))

- ចំណាយចេញពី ADB Loan 3007-CAM (SF) មានចំនួន ៧២.៣២៣,៨២ ដុល្លារអាមេរិក សំរាប់ទូទាត់លើចំណាយរដ្ឋបាលប្រចាំថ្ងៃក្នុងអង្គភាព ចំណាយលើការចុះបំពេញបេសកកម្មនិងការចូលរួមប្រជុំ/សិក្ខាសាលាតាមខេត្ត (ការឧបត្ថម្ភលើការស្នាក់នៅ ហូបចុក និងធ្វើដំណើរ) ចំណាយលើការទិញរថយន្ត (ចំនួន០១គ្រឿង) និងចំណាយលើប្រាក់បៀវត្សរបស់អ្នកជំនាញការ (ចំនួន០១រូប) ក្នុងអង្គភាព

- ចំណាយចេញពីបដិភាគរដ្ឋាភិបាលមានចំនួន ៧៩.៩១៩,១៨ ដុល្លារអាមេរិក សម្រាប់ទូទាត់លើចំណាយរដ្ឋបាលប្រចាំថ្ងៃក្នុងអង្គភាព ចំណាយលើការរៀបចំសិក្ខាសាលា ចំណាយលើការចុះបំពេញបេសកកម្មនិងការចូលរួមប្រជុំ/សិក្ខាសាលាតាមខេត្ត (ការឧបត្ថម្ភលើការស្នាក់នៅ ហូបចុក និងធ្វើដំណើរ) ចំណាយលើការទិញគ្រាប់ស្រូវពូជ (Certified Rice Seed) ចំណាយលើការទិញរថយន្ត (ចំនួន០១គ្រឿង) និងចំណាយលើប្រាក់បៀវត្សរបស់អ្នកជំនាញការ (ចំនួន០១រូប)។

### ៣)- **ការងារលទ្ធកម្ម**

នៅក្នុងឆ្នាំ២០១៥ អង្គភាព MAFF-NIO សម្រេចបាននូវការងារលទ្ធកម្ម រួមមាន៖

- បានផ្សព្វផ្សាយជ្រើសរើសអ្នកជំនាញការថ្នាក់ជាតិផ្នែកគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ ចំនួន០១រូប និងអ្នកជំនាញការផ្នែកលទ្ធកម្ម ចំនួន០១រូប។ ជាលទ្ធផល អ្នកជំនាញការថ្នាក់ជាតិផ្នែកគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុចំនួន០១រូប ត្រូវបានជ្រើសរើស និងបានមកបម្រើការងារនៅក្នុងអង្គភាព MAFF-NIO ចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។ ដោយឡែក អ្នកជំនាញការផ្នែកលទ្ធកម្មមិនបានជាប់ក្នុងការជ្រើសរើសទេ ដោយសារមិនអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស។ នៅចំពោះមុខ អង្គភាព MAFF-NIO បានផ្សព្វផ្សាយជ្រើសរើសរកអ្នកជំនាញការផ្នែកលទ្ធកម្មសារជាថ្មី។ ជាលទ្ធផល មានបេក្ខជនចាប់អារម្មណ៍ចំនួន០៩រូប ហើយការជ្រើសរើសសំរាំង (Shortlist) គឺស្ថិតនៅក្នុងដំណើរការនៅឡើយ

- បានធ្វើលទ្ធកម្មទិញគ្រាប់ពូជស្រូវចំណាត់ថ្នាក់គ្រាប់ពូជសុទ្ធគ្រឹះ (Rice Foundation Seed) និងគ្រាប់ស្រូវពូជសុទ្ធអនុញ្ញាត (ផ្ការំដួល) (Certified Rice Seed)។ ជាលទ្ធផល អង្គភាព MAFF-NIO បានចុះកិច្ចសន្យាទិញគ្រាប់ស្រូវពូជសុទ្ធអនុញ្ញាត (ផ្ការំដួល) (Certified Rice Seed) ពីសមាគមអភិវឌ្ឍន៍កសិកម្មជនបទ (RADA) និងបានចែកជូនសហគមន៍កសិកម្មក្នុងខេត្តគោលដៅទាំងបីរួចរាល់ជាស្ថាពរ។ ដោយឡែក ចំពោះគ្រាប់ពូជស្រូវចំណាត់ថ្នាក់គ្រាប់ពូជសុទ្ធគ្រឹះ (Rice Foundation Seed) គឺមិនអាចធ្វើលទ្ធកម្មទិញបានដោយសារអ្នកផ្គត់ផ្គង់មិនត្រូវតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយកម្មវិធី Rice-SDP

- បានធ្វើលទ្ធកម្មទិញរថយន្តចំនួន០២គ្រឿង ដោយក្នុងនោះ ០១គ្រឿងសម្រាប់អង្គភាព MAFF-NIO និង០១គ្រឿងទៀតសម្រាប់អង្គភាព PIO នៃខេត្តព្រៃវែង

- បានធ្វើលទ្ធកម្មទៅលើការទិញសម្ភារការិយាល័យ រួមមាន៖ កំព្យូទ័រ (លើតុ និងយួរដៃ) ម៉ាស៊ីនព្រីន ម៉ាស៊ីនថតចម្លង ម៉ាស៊ីនស្កេន ម៉ាស៊ីនថត ឧបករណ៍ GPS និង LCD Projector

- ចំពោះការធ្វើលទ្ធកម្មទៅលើការទិញគ្រឿងសង្ហារឹមការិយាល័យគឺជាការទទួលខុសត្រូវរបស់អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO)

- បានបញ្ចប់ការធ្វើលទ្ធកម្មទៅលើការជុសជុល និងកែលំអការិយាល័យ (Office Renovation) សម្រាប់អង្គភាព MAFF-NIO (គញ្ចប់រួមជាមួយ PMO)

- បានផ្សព្វផ្សាយជ្រើសរើសបុគ្គលិកអនាម័យចំនួន០១រូប និងអ្នកបើកបររថយន្តចំនួន០១រូប ហើយការជ្រើសរើសសំរាំងគឺស្ថិតនៅក្នុងដំណើរការនៅឡើយ

- បាន និងកំពុងរៀបចំឯកសារដេញថ្លៃសម្ភារសម្រាប់មន្ទីរពិសោធន៍គ្រាប់ពូជស្រូវ និងស្ថិតនៅក្នុងដំណើរការនៅឡើយ។

## II)- ការងាររៀបចំគោលនយោបាយ ច្បាប់ និងបទដ្ឋាននានា និងការងារបច្ចេកទេសត្រូវអនុវត្ត ដើម្បីសម្រេចបាននូវធាតុចេញ (Outputs) នានាដើម្បីឆ្លើយតបលទ្ធផលនៃគម្រោង

កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) ត្រូវបានអនុវត្តនៅខេត្តចំនួន០៣ (១៣ស្រុក) រួមមាន៖ ខេត្តកំពង់ធំ បាត់ដំបង និងព្រៃវែង។ ស្រុកគោលដៅដែលត្រូវអនុវត្តគម្រោងមាន៖ ក្រុងស្ទឹងសែន ស្រុកស្ទោង កំពង់ស្វាយ សន្ទុក និងបារាយណ៍ (នៅខេត្តកំពង់ធំ) ស្រុកថ្មគោល បវេល មោងឫស្សី និងរុក្ខគិរី (នៅខេត្តបាត់ដំបង) និងស្រុកស្វាយអន្ទរ ព្រះស្ដេច ស៊ីធរកណ្ដាល និងកំពង់ត្របែក (នៅខេត្តព្រៃវែង)។

### ១)- ការងារសម្រាប់ធាតុចេញ (Output) ទី១: A Conducive Legal and Regulation Environment Established to Facilitate Climate-Resilient Rice Commercialization

អង្គភាព MAFF-NIO បានបង្កើតក្រុមការងាររៀបចំច្បាប់ និងបទដ្ឋានគតិយុត្តក្រោមច្បាប់ចំនួន០៣ក្រុមរួមមាន៖ ១) ក្រុមការងាររៀបចំបទដ្ឋានគតិយុត្តក្រោមច្បាប់គ្រប់គ្រងពូជដំណាំ និងគោលនយោបាយពូជដំណាំ។ ២) ក្រុមការងាររៀបចំច្បាប់ស្ដីពីដីកសិកម្ម និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ និង ៣) ក្រុមការងាររៀបចំច្បាប់ស្ដីពីកិច្ចការពារដំណាំនិងភូតគាមអនាម័យ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីរៀបចំសកម្មភាពគោលនយោបាយនានា (Policy Actions) ដោយស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អង្គភាព MAFF-NIO បានរៀបចំផែនការសកម្មភាព (Work Plan) សំណើសុំថវិកា (Budget Proposal) និងឯកសារទស្សនទាន (Concept Note) សម្រាប់ការងាររៀបចំច្បាប់ និងបទដ្ឋានគតិយុត្តក្រោមច្បាប់ និងបានផ្ញើទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសុំការពិនិត្យ និងអនុម័ត។ កិច្ចប្រជុំជាច្រើនលើកត្រូវបានធ្វើឡើងជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកែសម្រួលសំណើសុំថវិកានេះ។ រហូតមកដល់ពេលនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងដំណើរការឯកសារនេះនៅឡើយ។ ទោះបីជាយ៉ាងនេះក្ដី កិច្ចប្រជុំផ្ទៃក្នុងជាច្រើនលើកត្រូវបានរៀបចំឡើងដើម្បីពិភាក្សាទៅលើការងារទាំងនេះ ហើយក្រុមការងារសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

#### ១.១- វឌ្ឍនភាពនៃការជំរុញផលិតកម្ម និងការចែកចាយគ្រាប់ពូជស្រូវដែលមានគុណភាព (Promote Production and Distribution of Improved Quality Seed)

ក្រុមការងាររៀបចំបទដ្ឋានគតិយុត្តក្រោមច្បាប់គ្រប់គ្រងពូជដំណាំ និងគោលនយោបាយពូជដំណាំ បានបញ្ចប់ការរៀបចំសេចក្ដីព្រាងលើកទី១ (1st Draft) ទៅលើ៖ ១) បទដ្ឋានគតិយុត្តក្រោមច្បាប់គ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ (Regulation under the Law on Seed Management and Plant Breeder's Rights) ដោយក្នុងនោះមានអនុក្រឹត្យចំនួន០១ ប្រកាសចំនួន០៧ និងគោលការណ៍ណែនាំបច្ចេកទេស ចំនួន០២ និង ២) គោលនយោបាយពូជដំណាំ (Seed Policy) ដោយក្នុងនោះមាន៖ ១) គោលនយោបាយពូជដំណាំថ្នាក់ជាតិ (National Seed Policy) ចំនួន០១ ដែលបានរៀបចំសេចក្ដីព្រាងលើកទី១រួចរាល់ និង ២) ផែនការសកម្មភាពស្ដីពីពូជស្រូវ (Action Plan on Rice Seed) ដែលស្ថិតនៅក្នុងដំណាក់កាលរៀបចំសេចក្ដីព្រាងលើកទី១នៅឡើយ។

១.២- ការពង្រឹងការគ្រប់គ្រងដីកសិកម្ម (Strengthen Agricultural Land Management)

ក្រុមការងាររៀបចំច្បាប់ស្តីពីដីកសិកម្ម និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ បានបញ្ចប់ការរៀបចំសេចក្តីព្រាងលើកទី១ (1st Draft) នៃ ១) ច្បាប់ស្តីពីដីកសិកម្មនៅកម្ពុជា (Law on Agricultural Land in Cambodia) និង ២) កម្មវិធីសកម្មភាពថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងការខូចខាតដីជាតិដី (National Action Program to Combat Land Degradation)។ ដោយឡែក គោលការណ៍ណែនាំសម្រាប់ការបង្កើតតំបន់ដីកសិកម្ម (Guidelines for the Establishment of Agricultural Land Zones) ទើបតែត្រូវបានចាប់ផ្តើមនៅឡើយ។

១.៣- ការសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងស្រុក និងការនាំចេញអង្ករ (Facilitate Domestic Trading and Export Milled Rice)

ច្បាប់ស្តីពីកិច្ចការពារដំណាំ និងភូតគាមអនាម័យ (National Law on Plant Protection, Sanitary and Phyto-sanitary) បាន និងកំពុងស្ថិតនៅក្រោមការរៀបចំសេចក្តីព្រាងលើកទី១ (1st Draft) នៅឡើយ។

**២)- ការខារសម្រាប់ធាតុចេញ (Output) ទី២: Agricultural Land-Use Zoning Improved**

នៅក្នុងឆ្នាំ២០១៥ អង្គភាព MAFF-NIO បានសម្រេចនូវការងារមួយចំនួនមានដូចខាងក្រោម៖

- បានរៀបចំសិក្ខាសាលាណែនាំ និងផ្សព្វផ្សាយការគៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរដល់អ្នកម៉ៅការរៀបចំដី និងអ្នកពាក់ព័ន្ធក្នុងខេត្តគោលដៅសម្រាប់ត្រៀមឱ្យមានការបើកវគ្គបណ្តុះបណ្តាលស្តីពីការគៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរដល់អ្នកម៉ៅការរៀបចំដីនៅក្នុងឆ្នាំ២០១៦

- បានប្រជុំពិភាក្សាជាមួយអ្នកជំនាញការគ្រប់គ្រងប្រព័ន្ធព័ត៌មាន (MIS Specialist) លើការរៀបចំទម្រង់គេហទំព័ររបស់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) ដែលមានជាភាសាខ្មែរ និងអង់គ្លេស

- បានជួបពិភាក្សាដើម្បីបញ្ចូលសមាសភាពអង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិ (NIOs) និងអង្គភាពអនុវត្តន៍គម្រោងថ្នាក់ខេត្ត (PIOs) ទៅក្នុងគេហទំព័ររបស់កម្មវិធី Rice-SDP និងបានពិភាក្សារួមគ្នាជាមួយទីប្រឹក្សាអនុវត្តគម្រោង (PIC) ដើម្បីធ្វើបច្ចុប្បន្នភាពនៃគេហទំព័ររបស់កម្មវិធី Rice-SDP

- បានជួបពិភាក្សាជាមួយអ្នកជំនាញការដើម្បីបង្កើតទិន្នន័យមូលដ្ឋាននៃប្រព័ន្ធគ្រប់គ្រងព័ត៌មានប្រព័ន្ធកសិកម្ម (FSMIS)

- បានរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ការងារបណ្តុះបណ្តាលដល់មន្ត្រីនៅខេត្តគោលដៅទាំងបីគឺ ខេត្តបាត់ដំបង កំពង់ធំ និងព្រៃវែង អំពី៖

- ការប្រជុំបង្កើតក្រុមការងារអនុវត្តន៍ការវិភាគប្រព័ន្ធកេរ្បក្របរិស្ថាន (AEA)
- ការធ្វើវិភាគប្រពន្ធ័កេរ្បក្របរិស្ថាន
- ការអង្កេត និងចាត់ថ្នាក់ដីកសិកម្ម
- វិធានការចម្រុះក្នុងការគ្រប់គ្រង និងកែលម្អដីជាតិដី។

- បានរៀបចំកិច្ចប្រជុំដើម្បីបង្កើតក្រុមការងារអនុវត្តន៍ការវិភាគប្រព័ន្ធកេរ្បក្របរិស្ថាន (AEA) នៅក្នុងខេត្តទាំងបីគឺ៖ ខេត្តបាត់ដំបង កំពង់ធំ និងព្រៃវែង

- បានប្រជុំជាមួយក្រុម PIC និងមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ដើម្បីពិភាក្សាពីផែនការសកម្មភាពដែលត្រូវរៀបចំសម្រាប់ការងាររៀបចំផែនទីប្រពន្ធ័អេកូឡូស៊ីដំណាំស្រូវ

- បានប្រជុំពិភាក្សាជាមួយទីប្រឹក្សាបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) លើការរៀបចំឯកសារមេរៀនស្តីពីការវិភាគប្រព័ន្ធកេរ្បក្របរិស្ថានថ្នាក់ឃុំ (CAEA) និងការធ្វើផែនការប្រើប្រាស់ដីថ្នាក់ឃុំ (CLUP) ដើម្បីបញ្ចូលគ្នាជាឯកសារតែមួយសម្រាប់យកទៅបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ខេត្ត

- បានប្រជុំពិភាក្សាទៅលើ៖

• កម្មវិធីការងារលំអិតសម្រាប់ចុះវាយតម្លៃនៅមូលដ្ឋាន

• ពិភាក្សាលើទម្រង់របាយការណ៍ដែលត្រូវបញ្ចូលគ្នារវាង AEA និង CLUP

• ពិភាក្សាលើការកំណត់ព្រំដែននៃការធ្វើ AEA រវាងមន្ត្រីនៃអង្គភាព MAFF-NIO និងមន្ត្រីនៃអង្គភាព MLMUPC-NIO។

- បានរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តការងារក្នុងឆ្នាំ២០១៦៖

• ការវិភាគប្រព័ន្ធកសិត្របរិស្ថាន (AEA) សម្រាប់ឃុំទាំង៩០នៅក្នុងខេត្តគោលដៅទាំងបី

• ការចុះអង្កេតដីកសិកម្មសម្រាប់រៀបចំផែនទីដីដំណាំស្រូវនៅក្នុងខេត្តទាំងបី

• ការរៀបចំផែនទីប្រពន្ធ័អេកូឡូស៊ីដំណាំស្រូវ។

**៣)-ការងារសម្រាប់លទ្ធផល (Output) ទី៣: Climate-Resilient Rice Value Chain Infrastructure Developed**

ការងារមួយចំនួនដែលអង្គភាព MAFF-NIO សម្រេចបាន រួមមាន៖

- បានសហការរៀបចំ Term of Reference សម្រាប់ជ្រើសរើសក្រុមហ៊ុន (Consulting Firm) មកធ្វើការសិក្សាពីលទ្ធភាព និងប្រឹក្សាគាំទ្រការសាងសង់ឃ្លាំងទុកដាក់ និងឡសម្ងួតទាំងស្រូវពូជ និងស្រូវចំណី

- បានរៀបចំបទបង្ហាញសម្រាប់ការប្រតិបត្តិរបស់អនុគម្រោង

- បានពង្រាងពីតួនាទី (Draft Term of Reference) របស់អ្នកជំនាញប្រតិបត្តិការរបស់រោងម៉ាស៊ីនកិនស្រូវ

- បាន និងកំពុងដំណើការជ្រើសរើសអ្នកជំនាញការដើម្បីធ្វើឱ្យប្រសើឡើងនៃការប្រតិបត្តិ និងគ្រប់គ្រង។

**៤)-ការងារសម្រាប់លទ្ធផល (Output) ទី៤: Rice Value Chain Support Services Enhanced to Improve Quality of Cambodian Rice**

ការងារមួយចំនួនដែលអង្គភាព MAFF-NIO សម្រេចបានរួមមាន៖

- បានទិញគ្រាប់ពូជស្រូវផ្ការំដួលចំណាត់ថ្នាក់ពូជសុទ្ធអនុញ្ញាត (Certified Rice Seed) ចំនួន១៣.៧២០ គីឡូក្រាម និងបានចែកជូនសហគមន៍កសិកម្មចំនួន២១សហគមន៍ក្នុងខេត្តគោលដៅទាំងបី (ខេត្តកំពង់ធំមានចំនួន១០សហគមន៍ ដាំដុះលើផ្ទៃដីសរុបបានចំនួន៣៦,៨៥ហិចតា ខេត្តបាត់ដំបងមានចំនួន០៩សហគមន៍ ដាំដុះលើផ្ទៃដីសរុបបានចំនួន៨៧,៥០ហិចតា និងខេត្តព្រៃវែងមានចំនួន០២សហគមន៍ ដាំដុះផ្ទៃដីសរុបបានចំនួន៥៥,៤០ហិចតា) ដោយអនុលោមតាមគោលការណ៍ដេញថ្លៃជាសាធារណៈដោយអង្គភាព MAFF-NIO

- បានផលិតពូជស្រូវផ្ការំដួលលើផ្ទៃដីសរុបចំនួន១៧៤,៣៥ ហិចតា ដែលក្នុងនោះ៖

• ព្រោះដោយដៃបានចំនួន ១២១,៦៥ ហិចតា

• ព្រោះជាជួរដោយអូសដាំ (Drum Seeder) បានចំនួន ៣៦,៣០ ហិចតា

• ស្ទូងបានចំនួន ១៦,៤០ ហិចតា។

- បាន និងកំពុងធ្វើគោលការណ៍ណែនាំលើកិច្ចប្រតិបត្តិការសម្រាប់សេចក្តីព្រាងចំណាត់ថ្នាក់គ្រាប់ពូជជាតិ (National Seed Certification)

- បាន និងកំពុងសិក្សាលើលទ្ធភាពអាចចុះកិច្ចសន្យាជាមួយកសិដ្ឋានផលិតពូជស្រូវទូលសំរោងដើម្បីផលិតពូជស្រូវចំណាត់ថ្នាក់ (Certified Rice Seed)

- បានរៀបចំផែនការ និងសកម្មភាពការងារមុន និងក្រោយពេលប្រមូលផលសម្រាប់បញ្ចូលក្នុងសកម្មភាពរួមរបស់អង្គភាព MAFF-NIO

- បានសហការជាមួយអ្នកជំនាញការខាងសេវាកម្មអភិវឌ្ឍន៍ជំនួញ (Business Development Service) ដើម្បីចុះ និងកំណត់លក្ខណៈវិនិច្ឆ័យរបស់រោងម៉ាស៊ីនកិនស្រូវមួយចំនួនក្នុងខេត្តបាត់ដំបង។

បន្ថែមពីនេះ អង្គភាព MAFF-NIO បានរៀបចំសំណើសុំអនុម័តថវិកាលើវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីផលិតកម្មពូជស្រូវ និងបានផ្ញើទៅកាន់អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO) ដើម្បីសុំការយល់ព្រម។ រហូតមកដល់ពេលនេះ ពុំទាន់មានការឆ្លើយតបពី PMO ចំពោះសំណើនេះនៅឡើយទេ។

**៥)-ការងារសម្រាប់ធាតុចេញ (Output) ទី៥: Weather-indexed Crop Insurance Piloted**

ការងារសម្រាប់លទ្ធផលទី៥ខាងលើនេះ ពុំទាន់បានរៀបចំ និងអនុវត្តនៅឡើយទេ។

**៦)-ការងារសម្រាប់លទ្ធផលទី៦: Efficient Program Management and Implementation**

អង្គភាព MAFF-NIO បាន និងកំពុងដំណើរការអនុវត្តសកម្មភាពការងារ ដោយក្នុងនោះអង្គភាព៖

- បានរៀបចំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំ និងក្រុមការងារនៃអង្គភាព MAFF-NIO អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO) និងទីប្រឹក្សាអនុវត្តកម្មវិធី (PIC) ដើម្បីពិភាក្សាការងារនិងសកម្មភាពដែលត្រូវអនុវត្តបន្ត ការផ្លាស់ប្តូរបទពិសោធន៍ ការលើកឡើងពីបញ្ហាប្រឈម និងការស្វែងរកដំណោះស្រាយ
- បានចុះបំពេញបេសកកម្មតាមខេត្តគោលដៅទាំងបីដើម្បីពិនិត្យ និងពិភាក្សាការងារជាមួយអង្គភាពអនុវត្តកម្មវិធីថ្នាក់ខេត្ត (PIO) ជាពិសេសជាមួយមន្ត្រីបង្គោលមន្ទីរកសិកម្មខេត្ត
- បានចុះពិនិត្យមើលទីតាំង និងស្ថានភាពជាក់ស្តែងនៅក្នុងតំបន់អនុវត្តគម្រោងក្នុងខេត្តគោលដៅទាំងបី
- បានពិភាក្សា និងរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៥ និងឆ្នាំបន្តបន្ទាប់
- បានរៀបចំរបាយការណ៍រាល់ការប្រជុំ/សិក្ខាសាលា និងការចូលរួមវគ្គបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការចុះបំពេញបេសកកម្មទៅតាមខេត្ត
- បានរៀបចំទម្រង់របាយការណ៍ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំរបស់អង្គភាព MAFF-NIO ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង PMO
- បានទំនាក់ទំនងជាមួយទីប្រឹក្សាអនុវត្តគម្រោង (PIC) និង PMO ដើម្បីឱ្យអ្នកជំនាញការអន្តរជាតិខ្លះដែលចាំបាច់ឱ្យមកជួយការងារនៅអង្គភាព MAFF-NIO ឱ្យបានទៀងទាត់។

## III)- ការវិភាគ និងវាយតម្លៃលើភាពជឿនលឿននៃការអនុវត្តគម្រោង

**១)-អធិប្បាយសង្ខេបនូវភាពជឿនលឿននៃការអនុវត្តគម្រោង ប្រៀបធៀបនឹងគោលដៅនៃគម្រោង**

បើប្រៀបធៀបទៅនឹងគោលដៅនៃគម្រោង លទ្ធផលដែលសម្រេចបានពីការអនុវត្តសកម្មភាពការងាររបស់អង្គភាព MAFF-NIO ក្នុងឆ្នាំ២០១៥ គឺមានសភាពយឺតយ៉ាវ ដោយសារការទំលាក់ថវិកាពីម្ចាស់ជំនួយមានភាពយឺតយ៉ាវ ដូចនេះការចាប់ផ្តើមអនុវត្តន៍សកម្មភាពការងាររបស់អង្គភាព MAFF-NIO គឺមានសភាពយឺតយ៉ាវទៅតាមនោះដែរ។ ម្យ៉ាងវិញទៀត ការអនុវត្តសកម្មភាពការងាររបស់អង្គភាព MAFF-NIO ក៏មានការយឺតយ៉ាវផងដែរ ដោយសាររាល់ការអនុវត្តសកម្មភាពនីមួយៗត្រូវសុំការយល់ព្រមពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តាមរយៈអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO)។

**២)-ស្ថានភាពងាយស្រួល និងផលលំបាក**

២.១ ភាពងាយស្រួល

- រាល់សំណើ និងលិខិតផ្សេងៗទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភាពងាយស្រួល ដោយសារមាន

ការសម្របសម្រួលច្រើនពី PMO

- មន្ត្រីក្នុងអង្គភាព MAFF-NIO ភាគច្រើនគឺជាមន្ត្រីរដ្ឋាភិបាលដែលមានការទទួលខុសត្រូវខ្ពស់ទៅលើតួនាទីភារៈកិច្ចនិងការងារ និងមានសមត្ថភាពនិងបទពិសោធន៍អនុវត្តការងារ

- មានការសហការការងារបានល្អជាមួយ PMOs, NIOs និង PIOs។

២.២ ផលលំបាក

- ដោយសារបុគ្គលិកភាគច្រើនជាមន្ត្រីរដ្ឋាភិបាល ដូចនេះ ពួកគាត់មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញការងារក្នុងគម្រោងឱ្យបានពេញលេញ

- មន្ត្រីបម្រើការងារនៅអង្គភាព MAFF-NIO មានចំនួនតិច ដោយអង្គភាពជ្រើសរើសបានអ្នកជំនាញការមួយចំនួន ហើយមួយចំនួនទៀតកំពុងជ្រើសរើស ដូចជា៖ អ្នកជំនាញការផ្នែកលទ្ធកម្ម អ្នកជំនាញការផ្នែកត្រួតពិនិត្យនិងវាយតម្លៃគម្រោង និងជំនួយការផ្នែករដ្ឋបាល និងបច្ចេកវិជ្ជា ជាដើម។

- ការអនុវត្តសកម្មភាពការងារត្រូវការការជួយផ្នែកបច្ចេកទេសពីទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិ ដែលបានជ្រើសរើសដោយ PMO។

២.៣ សំណូមពរទៅសមត្ថកិច្ចពាក់ព័ន្ធ

- ស្នើសុំការគាំទ្រ និងជួយអន្តរាគមន៍ឱ្យបានទាន់ពេលវេលាពីថ្នាក់ដឹកនាំ PMO លើបណ្តាសកម្មភាពរបស់អង្គភាព MAFF-NIO ដែលត្រូវអនុវត្តនៅតាមបណ្តាខេត្តក្នុងឆ្នាំ២០១៦

- ស្នើសុំផ្តល់មន្ត្រីផ្នែកកសិកម្មបន្ថែមក្នុងគម្រោងទាំងថ្នាក់ខេត្ត និងថ្នាក់ក្រោមខេត្ត ដោយសារសកម្មភាពការងារកសិកម្មមានច្រើនដែលត្រូវទទួលខុសត្រូវ ជាពិសេសនៅតាមបណ្តាឃុំ និងស្រុកគោលដៅ

- ស្នើសុំឱ្យមានការចូលរួមតាមដានលើបណ្តាសកម្មភាពផ្នែកសិកម្មដែលអង្គភាព MAFF-NIO សហការអនុវត្តនៅតាមបណ្តាខេត្តគោលដៅ

- ស្នើឱ្យមន្ត្រីបង្គោលនៅតាមខេត្តជួយរៀបចំផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់អនុវត្តសកម្មភាពការងារកសិកម្មក្នុងឆ្នាំ២០១៦ នៅតាមស្រុកគោលដៅដោយប្រើប្រាស់ថវិកា PIOs ខេត្ត

- គប្បីឱ្យមានទីប្រឹក្សាអចិន្ត្រៃយ៍ប្រចាំនៅអង្គភាព MAFF-NIO ក៏ដូចជា PIOs ដើម្បីជួយផ្តល់យោបល់ និងជួយសម្របសម្រួលលើនីតិវិធីអនុវត្តការងារក្នុងគម្រោងឱ្យបានរលូន និងមានភាពស៊ីចង្វាក់គ្នា

- រកដៃគូរ ឬទីផ្សារសម្រាប់ការផលិតឱ្យបានច្បាស់លាស់

- សូមឱ្យមានជាវេទិការវាងសហគមន៍ អ្នកផ្គត់ផ្គង់សម្ភារកសិកម្ម ម្ចាស់រោងម៉ាស៊ីន ទីភ្នាក់ងាររអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា

- គួរសិក្សាឱ្យបានស៊ីជំរៅ និងលម្អិតបន្ថែមទៀតទៅលើម្ចាស់រោងម៉ាស៊ីនកិនស្រូវដែលថ្នាក់ខេត្តបានកំណត់ដើម្បីត្រៀមសហការនាពេលខាងមុខ។

## IV)- សន្និដ្ឋាន

អង្គភាព MAFF-NIO បាន និងកំពុងដំណើរការការងាររបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវធាតុចេញនានា (Outputs) របស់គម្រោង និងដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនៃគម្រោងប្រកបដោយភាពជោគជ័យ និងប្រសិទ្ធភាព ដោយក្នុងនោះមានការរៀបចំកិច្ចប្រជុំពិភាក្សាជាមួយមន្ត្រីមកពីស្ថាប័នពាក់ព័ន្ធដូចជា៖ PMO និង PIOs (រួមទាំងមន្ត្រីបង្គោលកសិកម្មខេត្ត) ការបំពេញបេសកកម្មទៅតាមបណ្តាខេត្តគោលដៅដើម្បីពង្រឹងសមត្ថភាពមន្ត្រីបង្គោលកសិកម្មខេត្ត ក៏ដូចជាពិនិត្យទីតាំងអនុវត្តគម្រោង និងការចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្ត



Sp

គម្រោងក្នុងអង្គភាព MAFF-NIO និងការផ្ទេរនូវចំណេះដឹងទៅដល់ថ្នាក់មូលដ្ឋាន។ ជារួម ការអនុវត្តសកម្មភាពការងាររបស់អង្គភាព MAFF-NIO ក្នុងកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ក្នុងឆ្នាំ២០១៥ កន្លងមកនេះ មានដំណើរការល្អ ទោះបីជាលទ្ធផលទទួលបានពីការអនុវត្តសកម្មភាពមួយចំនួនមានសភាពយឺតយ៉ាវបន្តិចបន្តួចប្រៀបធៀបទៅនឹងគោលដៅកម្មវិធី ដោយសារពេលវេលានៃការចាប់ផ្តើមអនុវត្តគម្រោងត្រូវបានពន្យាពេល។ អង្គភាព MAFF-NIO បានសម្រេចនូវលទ្ធផលប្រកបដោយផ្លែផ្កាដែលចេញពីការខិតខំប្រឹងប្រែងពីសំណាក់ថ្នាក់ដឹកនាំនិងមន្ត្រីក្នុងអង្គភាព និងក្រោមការសម្របសម្រួល និងកិច្ចសហការល្អពីស្ថាប័នពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបជារបាយការណ៍ ដោយក្តីអនុគ្រោះ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦
ហត្ថលេខា

**គិត សេង**
**អនុរដ្ឋលេខាធិការ**
**និងជានាយកគម្រោងថ្នាក់ជាតិ MAFF-NIO**

**<u>ចម្លងជូន</u>**:
- អង្គភាព PMO
- អគ្គនាយកដ្ឋានកសិកម្ម
- អង្គភាពអនុវត្តន៍កម្មវិធីថ្នាក់ខេត្ត (PIO) នៃខេត្តកំពង់ធំ
- អង្គភាពអនុវត្តន៍កម្មវិធីថ្នាក់ខេត្ត (PIO) នៃខេត្តបាត់ដំបង
- ភាពអនុវត្តន៍កម្មវិធីថ្នាក់ខេត្ត (PIO) នៃខេត្តព្រៃវែង
- នាយកដ្ឋានផែនការ-ស្ថិតិ
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- ឯកសារ កាលប្បវត្តិ

# បញ្ជីវត្តមានប្រចាំឆ្នាំរបស់មន្ត្រីបម្រើការងារនៃអង្គភាពអនុវត្តន៍គម្រោង (MAFF-NIO for Rice-SDP)

| ល.រ | ឈ្មោះ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ឯកឧត្តម គិត សេង<br>នាយកគម្រោង | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ២ | ឯកឧត្តម សូ ខនឫទ្ធីគុណា<br>នាយករងគម្រោង | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣ | បណ្ឌិត ចាន់ សារុទ្ធ<br>អ្នកសម្របសម្រួលកម្មវិធីគម្រោង | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤ | លោក ជិន ឆាយ<br>មន្ត្រីទទួលបន្ទុកផែនការ និងការអនុវត្តគម្រោង | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៥ | លោក ជា គឹមហេង<br>មន្ត្រីទទួលបន្ទុករដ្ឋបាល គណនេយ្យ និងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦ | លោក ពេជ្រ រម្យនា<br>មន្ត្រីទទួលបន្ទុកគ្រប់គ្រងកិច្ចសន្យា | ✓ | ✓ | ✓ | ✓ | ✓ | ✓ | × | × | × | × | × | × |
| ៧ | លោក អ៊ំ ភិរម្យ<br>មន្ត្រីទទួលបន្ទុកគ្រប់គ្រងធនធានដី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៨ | លោក ជា សុវណ្ណឌីណា<br>មន្ត្រីទទួលបន្ទុកបច្ចេកវិទ្យាមុននិងក្រោយពេលប្រមូលផល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៩ | លោក ពេជ ផល្លី<br>មន្ត្រីទទួលបន្ទុកបច្ចេកទេសដំណាំស្រូវ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ១០ | លោក ស៊ុន ទ្រី<br>មន្ត្រីផ្សព្វផ្សាយកសិកម្ម | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ១១ | លោក កែ ធនភក្តិ<br>អ្នកជំនាញការផ្នែកគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ | | | | | | | | | | | | ✓ |
| ១២ | កញ្ញា ជា ពិសី<br>មន្ត្រីទទួលបន្ទុកយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ១៣ | លោកស្រី អ៊ឹន សុភា<br>មន្ត្រីរដ្ឋបាល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦
នាយកគម្រោង

គិត សេង